**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
# ស្តីពី
# ការរៀបចំទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ លើកទី៧ ឆ្នាំ២០២៤ ក្រោមប្រធានបទ "TVET រៀនឱ្យចប់ ឱ្យចេះ ឱ្យមានការងារ"

យោងតាមអនុក្រឹត្យលេខ ១៥០ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងសារាចរលេខ ០៤ សរ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៤ ស្តីពីការរៀបចំទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ លើកទី៧ ឆ្នាំ២០២៤ ក្រោមប្រធានបទ ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ "**រៀនឱ្យចប់ ឱ្យចេះ ឱ្យមានការងារ**" ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់សិស្ស និស្សិត យុវជន មាតាបិតា អាណាព្យាបាល សាធារណជន ម្ចាស់សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនឯកជន អង្គការជាតិ និងអន្តរជាតិ ឱ្យបានជ្រាបថា ក្រសួងនឹងរៀបចំប្រារព្ធទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ លើកទី៧ ឆ្នាំ២០២៤ រយៈពេល ២ថ្ងៃ គឺនៅថ្ងៃទី១៥-១៦ ខែមិថុនា ឆ្នាំ២០២៤ ចាប់ពីវេលាម៉ោង ៨:០០នាទីព្រឹក ដល់ម៉ោង ២០:០០នាទីយប់ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ ក្នុងគោលបំណងផ្សព្វផ្សាយអំពីសារៈសំខាន់ នៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

ទិវាជាតិនេះ នឹងមានការដាក់តាំងបង្ហាញ និងការប្រកួតប្រជែងនូវស្នាដៃរបស់សិស្ស និស្សិត ដែលមានគំនិតច្នៃប្រឌិត នវានុវត្តន៍ ពាក់ព័ន្ធនឹងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ វិស័យឯកជន និងវិស័យពាក់ព័ន្ធនានា និងអាចប្រើប្រាស់ដើម្បីជាប្រយោជន៍ដល់ការសិក្សាស្រាវជ្រាវ បម្រើដល់ការងារសង្គម វិស័យកសិកម្ម ពាណិជ្ជកម្ម សំណង់ និងឧស្សាហកម្ម ដោយត្រូវឆ្លងកាត់ការវាយតម្លៃពីគណៈកម្មការរៀបចំការប្រកួត និងការបោះឆ្នោតលើភាពពេញចិត្តពីសំណាក់អ្នកចូលរួមទស្សនា។ ចំពោះបេក្ខជនដែលទទួលបានជ័យលាភី នឹងទទួលបាននូវរង្វាន់លើកទឹកចិត្តផ្សេងៗ។ ក្នុងន័យនេះ សិស្ស និស្សិត និងយុវជន អាចមកដាក់ពាក្យស្នើសុំចូលរួមដាក់តាំងបង្ហាញ និងប្រកួតប្រជែង ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៤ តាមលក្ខខណ្ឌកំណត់ដូចខាងក្រោម៖

១.ត្រូវមានស្នាដៃ ឧបករណ៍ សម្ភារ ជាបច្ចេកវិទ្យាថ្មីៗ និងមានភាពទាក់ទាញ ដែលបង្កើតបានដោយខ្លួនឯង ឬជាក្រុម។

២.ត្រូវឆ្លងកាត់ការត្រួតពិនិត្យ និងវាយតម្លៃពីក្រុមការងារមុននឹងទទួលបានការអនុញ្ញាតឱ្យចូលរួមដាក់តាំងបង្ហាញ និងប្រកួត។

៣.មិនត្រូវជាប់កម្មសិទ្ធិបញ្ញា ឬចម្លងពីស្នាដៃដទៃឡើយ។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨៤៣៧៥ និងទូរសារ :(០២៣)៨៨២៧៦៩

សម្រាប់ព័ត៌មានលម្អិត សូមទំនាក់ទំនងមកកាន់នាយកដ្ឋានព័ត៌មានទីផ្សារការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានអាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឬតាមរយៈលេខទូរស័ព្ទ ០១៧ ៧៤៧ ៧៧៣/០៩៨ ៩៨៧ ៧៧៩/០៩៥ ២៣២ ៤៦៥ ឬអ៊ីម៉ែល៖ nguon.phunpisey@mlvt.gov.kh ឬ kim.ravuth@mlvt.gov.kh។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសិស្ស និស្សិត យុវជន មាតាបិតា អាណាព្យាបាល សាធារណជន ម្ចាស់សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនឯកជន អង្គការជាតិ និងអន្តរជាតិ មេត្តាជ្រាបជាព័ត៌មាន និងសូមអញ្ជើញចូលរួមឱ្យបានច្រើនកុះករ។

ថ្ងៃពុធ ៨កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៤